ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា

ប្រចាំនៅទីក្រុងណានីង

លេខ 0088 កពណក.ណន

សូមគោរពជូន

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**កម្មវត្ថុ** : របាយការណ៍ ប្រចាំខែ មីនា ឆ្នាំ ២០១២

សេចក្តីដូចបានជំរាបជូនកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមរាយការណ៍ជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ប្រចាំ ខែ មិនា ឆ្នាំ២០១២ ដូចតទៅ :

## I. ការងារទំនាក់ទំនងទៀង

- ជួបក្រុមហ៊ុន Yuanchen(Beijing)International Investment Group. មានបំណងវិនិយោគ ធ្វើឧស្សាហកម្មកែច្នៃដើមខ្លឹមច័ន្ទ នៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Nanning City, Green Plant. មានបំណងវិនិយោគទុនលើវិស័យទេសចរណ៍ នៅខេត្តកោះកុង
- ជួបជាមួយ China-ASEAN Business and Investment Summit Secretariat (CABIS) មានបំណងទៅកម្ពុជាដើម្បីជួបសំដែងការគួសម **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** និងពិភាក្សាជុំវិញបញ្ហា China-ASEAN Plaza នៅណានីង ។
- ចូលរួមសន្និបាតបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ២០១១ និងលើកទិសដៅអនុវត្តការងារពាណិជ្ជកម្ម ឆ្នាំ២០១២ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។
- ជួបជាមួយ Guangxi Jewelry Association មានបំណងអញ្ជើញក្រុមហ៊ុនអលង្គការកម្ពុជាចូលរួមពិពរណ៍ពាណិជ្ជកម្ម នៅណាននីង ពីថ្ងៃ១០-១៣ ខែ ឧសភា ឆ្នាំ២០១២ ខាងមុខនេះ ។

## II. សភាពការណ៍សេដ្ឋកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន

វិបត្តិប្រាក់បំណុលនៅសហគមអឺរ៉ុប និងវិបត្តិសេដ្ឋកិច្ចនៅអាមេរិកឈានដល់ដំណាក់កាលទាល់ច្រក ។

Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China
Tel/Fax: +86-771-5389496
Email : clo_cambodia@yahoo.com

ចិនជាមហាអំណាចសេដ្ឋកិច្ចចាត់ចំណាត់ថ្នាក់ទី២ និងជាប្រទេសដែលនាំចេញ-នាំចូលច្រើនជាងគេក្នុងពិភពលោក ។ ក្នុងករណីដែល សហគមអឺរ៉ុប និងសហរដ្ឋអាមេរិកមានវិបត្តិដ៏ធ្ងន់ធ្ងរនិងដើម្បីធានាស្ថេរភាពនិងស្តារសេដ្ឋកិច្ចពិភពលោក ចិនបានផ្តល់ជំនួយជាបន្ទាន់ដែលមានទឹកប្រាក់ ៤សែនកោដិដុល្លា ។ ក្នុងរយៈពេល ៣ឆ្នាំ ចិនបានពង្រីកអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំកើនបានលើសពី ៩% ។ នៅក្នុងចំណោម G.20 ពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោក ចិនចាត់ចំណាត់ទី៣ ដែលមានវិធានការណ៍ផ្តល់កញ្ចប់ជំនួយសេដ្ឋកិច្ច ។ សហគមអឺរ៉ុបជាដៃគូក្នុងការទំនាក់ទំនងល្អជាមួយចិនកន្លងមក និងដើម្បីជួយដោះស្រាយវិបត្តិប្រាក់បំណុលរបស់សហគមអឺរ៉ុប ភាគីចិនមានយុទ្ធសាស្ត្រជួយសហគមអឺរ៉ុបឱ្យបានជាសះស្បើយពីជម្ងឺសេដ្ឋកិច្ចដែលកំពុងរាលដាល ដោយភាគីចិនបង្កើតជាគណប្រតិភូចាំទទួលនាំចូលទំនិញពីសហគមអឺរ៉ុបក្នុងទិសដៅបង្កើតការងារ និងស្តារសេដ្ឋកិច្ចនៅអ៊ឺរ៉ុបឱ្យមានស្ថេរភាព ។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១២កំណើនសេដ្ឋកិច្ចចិនបានធ្លាក់ចុះបន្តិច តែនៅត្រីមាសទី២ ឆ្នាំ ២០១២ សេដ្ឋកិច្ចចិននៅមានស្ថេរភាពល្អនៅឡើយ ។ ផ្អែកតាមការព្យាករកំណើនសេដ្ឋកិច្ចរបស់ចិននឹងកើនបាន ៨.៤%ក្នុងត្រីមាសទី ២ ឆ្នាំ ២០១២នេះ ។ ចិនមានបំណងនាំចូលទំនិញពីសហគមអឺរ៉ុបឱ្យបានច្រើនក្នុង ឆ្នាំ២០១៣ខាងមុខនេះ ។ ក្នុងរយៈពេល១៧ឆ្នាំកន្លងមក ក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ ចិនបានវិនិយោគនៅកម្ពុជាច្រើនជាងគេដែលមានទឹកប្រាក់ ៨.៩កោដិដុល្លា លើវិស័យថាមពលអគ្គីសនី និងធនធានរ៉ែ ។ នៅក្នុងឆ្នាំ២០១១ ក្រុមហ៊ុនចិនបានវិនិយោគនៅកម្ពុជាដែលមានទឹកប្រាក់ ១.១៩កោដិដុល្លា កើនបាន៧១% បើប្រៀបធៀបជាមួយ ឆ្នាំ២០១០កន្លងមក ដែលអនុវត្តបានតែ ៦៩៤លានដុល្លា ។ ដោយឡែកនៅ ឆ្នាំ២០១១កន្លងទៅនេះ ចិនបានវិនិយោគលើដីសម្បទាននៅកម្ពុជាចំនួន ៧៥ម៉ឺនហិកតា ។

សេចក្តីដូចបានជំរាបជូនខាងលើសូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយអនុគ្រោះ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណាននីង, ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ ២០១២

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គឹមយ៉ុន**

ចម្លងជូន:

- អគ្គកុងស៊ុលនៅណាននីង
- ឯកសារកាលប្បវត្តិ

Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China
Tel/Fax: +86-771-5389496
Email : clo_cambodia@yahoo.com